**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥-០១៤-០០៤ ស.ភ.លា.ន

ភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤

# សេចក្តីណែនាំ
## អនុវត្តប្រកាស
## ស្តីពី
## ការផ្តល់សន្ទនីយភាពចំពោះសមាជិកសភាផាត់ទាត់ជាតិ

ដើម្បីឱ្យការអនុវត្តប្រកាសលេខ ធ៥-០១៤-២៣០-ប្រក ស្តីពី "ការផ្តល់សន្ទនីយភាពចំពោះសមាជិកសភាផាត់ទាត់ជាតិ" ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងបញ្ចៀសបាននូវហានិភ័យជាប្រព័ន្ធ ធនាគារជាតិនៃកម្ពុជាសូមណែនាំដល់សមាជិកសភាផាត់ទាត់ជាតិទាំងអស់ដូចតទៅ ៖

- ត្រូវដាក់ពាក្យស្នើសុំឥណទានវិបារូបន៍ជាលាយលក្ខណ៍អក្សរមកធនាគារជាតិនៃកម្ពុជាសម្រាប់រយៈពេលមួយឆ្នាំ ដោយត្រូវបង់សោហ៊ុយទម្រង់ការចំនួន ១.០០០.០០០ រៀល (មួយលានរៀល) សម្រាប់ការស្នើសុំនេះ ។
- ការស្នើសុំឥណទានវិបារូបន៍នេះ ត្រូវភ្ជាប់ជាមួយនូវកិច្ចសន្យាតាមគំរូដែលមានស្រាប់ចំនួន២(ពីរ) គឺ(១)កិច្ចសន្យាឥណទានវិបារូបន៍ និង(២)កិច្ចសន្យាដាក់ធានាលើឥណទានវិបារូបន៍ ។ កិច្ចសន្យាទាំងពីរប្រភេទនេះមានសុពលភាពបីខែ នឹងត្រូវធ្វើឡើងវិញរៀងរាល់បីខែ ។
- សមាជិកអាចប្រើប្រាស់មូលបត្រអាចជួញដូរបាន (NCD) ឬ/និង វិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់ចេញដោយធនាគារជាតិនៃកម្ពុជា សម្រាប់ធានាលើឥណទានវិបារូបន៍ ។ វត្ថុធានាត្រូវមានកាលវសានវែងជាងកាលវសានរបស់ឥណទានវិបារូបន៍យ៉ាងតិចបំផុតពីរថ្ងៃនៃថ្ងៃធ្វើការ ។ តម្លៃវត្ថុធានាត្រូវស្មើនឹងទំហំឥណទានវិបារូបន៍ ។ ក្នុងករណី វត្ថុធានាមានតម្លៃចារឹកជារូបិយប័ណ្ណផ្សេងគ្នាពីរូបិយប័ណ្ណឥណទានវិបារូបន៍ នឹងត្រូវបានគណនាតាមអត្រាប្តូរប្រាក់កំណត់ដោយធនាគារជាតិនៃកម្ពុជា នាថ្ងៃចុះកិច្ចសន្យាឥណទានវិបារូបន៍ ។
- អត្រាការប្រាក់ឥណទានវិបារូបន៍នឹងត្រូវកំណត់ដោយធនាគារជាតិនៃកម្ពុជា ហើយនិងមានចែងលំអិតក្នុងកិច្ចសន្យាឥណទានវិបារូបន៍ ។ ការប្រាក់ឥណទានវិបារូបន៍នឹងត្រូវបានគណនាផ្អែកលើទំហំឥណទាន និងចំនួនថ្ងៃដែលបានប្រើប្រាស់ ។

សមាជិកដែលមិនអាចអនុវត្តតាមលក្ខខណ្ឌចែងនៃប្រកាសស្តីពី "ការផ្តល់សន្ទនីយភាពចំពោះសមាជិកសភាផាត់ទាត់ជាតិ" នេះ នឹងត្រូវស្នើឱ្យដកខ្លួនចេញពីសមាជិកផ្ទាល់ (Direct member) មក ជាសមាជិកមិនផ្ទាល់វិញ (Indirect member) ដោយអនុលោមតាមវិធាននិងនីតិវិធីសភាផាត់ទាត់ជាតិ ។

សមាជិកទាំងអស់ត្រូវអនុវត្តតាមខ្លឹមសារណែនាំខាងលើនេះជាកំហិត យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ នេះជាដាច់ខាត ។

សេចក្តីណែនាំនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**អគ្គនាយកបច្ចេកទេស**

ជា សិរី